ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | កៀនឃ្លាំង |
| ភូមិ | : | កៀនឃ្លាំង |
| ឃុំ | : | អំពិលទឹក |
| ស្រុក | : | កំពង់ត្រឡាច |
| ខេត្ត | : | កំពង់ឆ្នាំង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
## រយៈពេល ៣ ឆ្នាំ
## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : គៀនឃ្លាំង
ភូមិ : គៀនឃ្លាំង
ឃុំ : អំពិលទឹក
ស្រុក : កំពង់ត្រឡាច
ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **កៀនឃ្លាំង** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១២** ខែ **មករា** ឆ្នាំ **២០០៦** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។ សហគមន៍នេសាទ **កៀនឃ្លាំង** មានទីតាំងស្ថិត នៅក្នុងភូមិ **កៀនឃ្លាំង** ឃុំ **អំពិលទឹក** ស្រុក **កំពង់លែងត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **១៦៨** នាក់ ស្រីចំនួន **៧៩** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់ ស្រីចំនួន **២** នាក់។ ក្នុងនោះចំនួនគ្រួសារ ដែលចូលជាសមាជិកសហគមន៍នេសាទសរុបមានចំនួន **១០៥** គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមានឆ្នាំ ២០០៦ ប្រជាពលរដ្ឋបានផ្ដិតមេដៃស្នើសុំឱ្យមានការបង្កើតសហគមន៍នេសាទយោងលើរាជរដ្ឋាភិបាលធ្វើកំណែទំរង់វិស័យជលផល នៃអនុក្រឹត្យស្ដីពីការកាត់ និងលប់ឡូត៍នេសាទ ព្រះរាជក្រឹត្យស្ដីពីការបង្កើតសហគមន៍នេសាទ និងអនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ។ សហគមន៍នេសាទក៏បានកើតឡើងតាមរយៈការបោះឆ្នោតជ្រើសរើសគណៈកម្មការដោយ មានការជួយគាំទ្រពីការិយាល័យជលផលខេត្ត អាជ្ញាធរមូលដ្ឋានដោយមានការគាំទ្ររបស់គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបផ្នែកទី២។ នៅឆ្នាំ ២០០៦ ផ្សព្វផ្សាយអនុក្រឹត្យសហគមន៍នេសាទ ចុះឈ្មោះសមាជិកសហគមន៍នេសាទបង្កើតក្រុមល្បាត បានធ្វើមហាសន្និបាតការអនុម័តលើ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងកំណត់ព្រំប្រទល់ផែនទីសហគមន៍ ។ សហគមន៍នេសាទបានទទួលការបណ្ដុះបណ្ដាល ស្ដីពីការគ្រប់គ្រងធនធានជលផល និងផ្សព្វផ្សាយផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលទៅលើដំណាំកសិកម្មក្នុងនោះដែរគណៈកម្មការសហគមន៍នេសាទភាគច្រើនបានធ្វើការប្រជុំប្រចាំខែ ចុះល្បាតលើដែននេសាទសហគមន៍ និងសហការជាមួយអាជ្ញាធរដែនដីទៅលើការងារមួយចំនួននៅក្នុងភូមិសហគមន៍។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក-ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **១១៥** គ្រួសារ ស្មើនឹង **៦០១** នាក់ប្រុស **២៩៩** នាក់ ស្រី **៣០២** នាក់ ក្នុងនោះមានជាជនជាតិខ្មែរចំនួន **៥៩៨** នាក់ ខ្មែរឥស្លាមចំនួន **៣** នាក់ និងអាណិកជនវៀតណាមចំនួន **១** នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១៧ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ២ នាក់ ស្រី គ្មាន
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៨ នាក់ ស្រី ៥ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ២២ នាក់ ស្រី ១៣ នាក់

- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមានប្រុស ១ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **៨៤ %** ឥស្លាម **១ %** និង គ្រិះ **១៥ %** ។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **៣៥** នាក់ ស្រី **២៧** នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន **៥៧** នាក់ ស្រី **២៤** នាក់ កំរិតមធ្យមសិក្សាចំនួន **៧១** នាក់ ស្រី **២៨** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **៥** នាក់ ជាបុរស ។

**ខ -មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- នេសាទចំនួន ១១៥ គ្រួសារ
- ធ្វើស្រែចំនួន ១១៥ គ្រួសារ
- ចិញ្ចឹមត្រីចំនួន ១៥ គ្រួសារ (១០ម x ១៥ម)
- កែឆ្នៃផលនេសាទចំនួន ៥០ គ្រួសារ (ត្រីឆ្អើរ)
- ត្បាញកន្ទេលចំនួន ១២ គ្រួសារ (កន្ទេលក្រហម)
- លក់ដូរចំនួន ៥ គ្រួសារ
- ពេទ្យភូមិ ១ នាក់
- ទិញ លក់ផលនេសាទ ២ គ្រួសារ
- រត់ទូកដរ ៤ នាក់

**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

**ក. ទីតាំង** កន្លែងនេសាទសហគមន៍ **កៀនឃ្លាំង** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទ លេខ **១៩** ។ កន្លែងនេសាទសហគមន៍ **កៀនឃ្លាំង** មានទំហំ **២៩៦** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **សិរិវ្ធជ័យ**
- ខាងត្បូងទល់នឹង **ទន្លេធំ (ដៃទន្លេសាប)**
- ខាងកើតទល់នឹង **វាលស្បូវ**
- ខាងលិចទល់នឹង **ទន្លេលង្វែក (ទន្លេតូច)**

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍ កៀនឃ្លាំង មានបឹងចំនួន **២** ព្រែកចំនួន **២** និងមេទឹកចំនួន៤ ។

- បឹងឈ្មោះ កាន្សៀរ ប្រវែង ៥០ម x ២០០ម នេសាទពីខែ កក្កដា ដល់ខែ មេសា

- ដៃបឹងជាប់ជើង ប្រវែង ៧០ម x ២០០ម នៅសាទពីខែ កក្កដា ដល់ខែ មេសា
- កូនព្រែកតាចាប ប្រវែង ៤ម x ១០០ម មិននៅសាទ
- មេទឹកតាឌឹម ប្រវែង ១០០ម x ១០០ម ទុកទឹក
- មេទឹកតាអឹម ប្រវែង ១៥០០ម x ១៥០ម នៅសាទពីខែ មិនា ដល់ខែ មេសា
- មេទឹកទំនប់តាប្រាក់ ប្រវែង ១២០០ម x ២០០ម នៅសាទពីខែ កុម្ភៈ ដល់ខែ មិនា
- មេទឹកទំនប់តាប្រេង ប្រវែង ១១០០ម x ១៥០ម នៅសាទពីខែ កុម្ភៈ ដល់ខែ មិនា
- ព្រៃលិចទឹកតាឌឹម ទំហំ ៨០ម x ៩០ម
- ព្រៃលិចទឹកតាអឹម ទំហំ ៥០ម x ៥០០ម
- ព្រៃលិចទឹកតាប្រាក់ ទំហំ ១០០ម x ៥០០ម
- ព្រៃលិចទឹកតាប្រេង ទំហំ ៥០ម x ២០០ម
- ទំនាបបាតថាសរាំងជ្រុំ ទំហំ ២០០ម x ១០០ម នៅសាទ ពីខែ មិនា ដល់ខែ កញ្ញា

## គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

ដោយសហគមន៍នេះមិនមានបឹងធំហើយមានជម្រៅជ្រៅនោះ ធ្វើឱ្យសហគមន៍នេសាទនេះមិនអាចបង្កើតតំបន់អភិរក្សបានទេ តែអាចអភិរក្សព្រៃលិចទឹក ទំហំ ១០០ម x ៥០០ម។

## ឃ. ធនធានជលផល

**តារាងឧបសម្ព័ន្ធទី១ ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍**

**តារាង ១:**

| លរ | ត្រី | | | វារីសត្វ | | | វារីរុក្ខជាតិ | | | ព្រៃលិចទឹក | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឈ្មោះត្រី | កើន | ថយ | ឈ្មោះវារីសត្វ | កើន | ថយ | ឈ្មោះវារីជាតិ | កើន | ថយ | ឈ្មោះព្រៃលិចទឹក | កើន | ថយ |
| ១ | ក្រាញ់ | -- | | ភេ | | -- | សារាយ | -- | | រាំង | -- | |
| ២ | រ៉ស់ | -- | | ពស់ព្រលិត | | | ត្រកួន | | -- | ច្រកែង | | |
| ៣ | កំភ្លាញ | -- | | ខ្យង | -- | | កន្ទាំងហៃ | | | ញ | -- | |
| ៤ | អណ្តែង | -- | | អណ្តើក | | -- | កក់ | -- | | ក្រចាប់ | | |
| ៥ | កន្ធរ | -- | | លៀស | | -- | ស្មៅ | | -- | ត្រស់ | -- | |
| ៦ | ក្រុស | -- | | ខ្ចៅ | -- | | កំប្លោក | -- | | បបួយ | -- | |
| ៧ | ឆ្តោ | | -- | ក្តាម | | | ចក | -- | | ទៀនព្រៃ | -- | |
| ៨ | រៀល | -- | | អន្ទង់ | | | ត្រាវកាត | -- | | អាញ្ជៀរ | -- | |
| ៩ | ស្លាត | -- | | កន្ធាយ | | -- | ត្រាវ | -- | | ឃ្លៃ | | -- |
| ១០ | កញ្ចុនជ័យ | -- | | ទាព្រៃ | | | ស្មៅរំពាក់ទឹក | -- | | ខ្ទម | | |
| ១១ | ច្រវ៉ា | -- | | ក្អែកទឹក | -- | | ស្មៅពក | | | អញ្ចាញ | -- | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១២ | ច្រឡឹង | | -- | ក្អែកគោក | —— | | ស្មៅចាផ្លង | -- | | ក្របាស់ព្រៃ | -- | |
| ១៣ | កន្ទ្រប់ | -- | | ប្រវឹក | —— | | ស្មៅរពាក់ទឹក | -- | | ទន្លា | -- | |
| ១៤ | ក្រឹម | -- | | ពស់ឈើ | —— | | ស្មៅអញ្ចៀន | —— | | រុន | —— | |
| ១៥ | ក្រម៉ម | | -- | ពស់សំលាប់កង្កែប | -- | | ស្លាបច្រវ៉ា | —— | | ផ្ទោល | —— | |
| ១៦ | កំភ្លាវ | -- | | ពស់ប្រេង | | -- | ស្លង | -- | | សណ្តាន់ | —— | |
| ១៧ | កញ្ចុះ | -- | | ពស់ថ្លាន់ | —— | | កំពីងពួយ | -- | | ត្រសេក | | -- |
| ១៨ | គល់រាំង | | -- | ពស់ចាន់ល្មម | | -- | ដង្ហិតតឈ្នាង | —— | | បបុស្ស | -- | |
| ១៩ | ខ្នាន់ | -- | | ពស់ព្រៃ | | -- | ស្មៅបារាំង | —— | | ត្រែង | -- | |
| ២០ | ឆ្លូញ | -- | | ក្រដេវិច | -- | | | | | អណ្តាតត្រកួត | -- | |
| ២១ | ផ្កាគរ | -- | | ព់សអុជ | | -- | | | | អាវក្រពើ | —— | |
| ២២ | ចេក | -- | | ពស់ខៀវ | -- | | | | | ក្រវ៉ាន់ | —— | |
| ២៣ | ឆ្លាំង | | -- | ជន្លេន | | -- | | | | អូយមួយ | —— | |
| ២៤ | ឆ្កិន | | -- | អន្សង | | -- | | | | ផ្តៅ | | -- |
| ២៥ | លលកសរ | | -- | កង្កែប | | -- | | | | បន្លាស្អិត | —— | |
| ២៦ | ឆ្កិន | -- | | កំពិស | —— | | | | | វល្លិត្រី | | -- |
| ២៧ | សង្កត់ប្រាក់ | -- | | | | | | | | វល្លិដូងព្រះ | | -- |
| ២៨ | ផ្ទោង | -- | | | | | | | | វល្លិប្រេង | -- | |
| ២៩ | ជន្ទាស់ភ្លុក | -- | | | | | | | | ភ្នំភ្លេង | —— | |
| ៣០ | | | | | | | | | | វល្លិជុយ | -- | |
| ៣១ | | | | | | | | | | ខ្នាយមាន់ | -- | |
| ៣២ | | | | | | | | | | ស្លូត | -- | |
| | | | | | | | | | | សាម៉ាវព្រៃ | -- | |
| | | | | | | | | | | បន្លាយួន | -- | |
| | | | | | | | | | | ត្រដិត | -- | |
| | | | | | | | | | | តាអើក | -- | |
| | | | | | | | | | | ត្រដក់ | -- | |
| | | | | | | | | | | ផ្ទោល | | -- |
| | | | | | | | | | | វល្លិពោះអំបែង | -- | |
| | | | | | | | | | | ប្រផេញញីឆ្មោល | | -- |
| | | | | | | | | | | ថ្លើមអណ្តើក | —— | |
| | | | | | | | | | | ស្តី | | -- |
| | | | | | | | | | | សណ្តាន់ | —— | |
| | | | | | | | | | | ម្តេញ | | -- |

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទចំនួន ១១៥ គ្រួសារ
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន ១០ គ្រួសារ
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ១០០ នាក់ ស្រី ២០ នាក់

### ខ. ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍:

**តារាង ១:**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ...ដល់ ខែ...) |
|---|---|---|---|---|
| មងពាក់ | ម៉ែត្រ | | ក្រឡា០.០០២ម=១៨០០ម | ខែ មិថុនា ដល់ខែ កុម្ភៈ |
| | | | ក្រឡា០.០០៣ម=៣៦០០ម | |
| | | | ក្រឡា០.០០៤=៧២០០ម | |
| | | | ក្រឡា០.០០៥=៧២០០ម | |
| | | | ក្រឡា០.០០៦=៩០០ម | |
| | | | ក្រឡា០.០០៧=៩០០ម | |
| សន្ទូចរនង | ផ្លែ | ៩០០០ | | ខែ មិថុនា ដល់ខែ កុម្ភៈ |
| សន្ទូចបង្កៃ | ផ្លែ | ២០០០ | | ខែ ធ្នូ ដល់ខែ កុម្ភៈ |
| សាង | គ្រឿង | ១០ | ១០ x ២០០ | ខែ កក្កដា ដល់ខែ វិច្ឆិកា |
| លាន់ | គ្រឿង | ៩០ | | ខែ កក្កដា ដល់ខែ វិច្ឆិកា |

-ប្រភេទទូកកាណូត

**តារាង ២:**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| គ្មានម៉ាស៊ីន | ១០ | ៥០០ គ.ក | - |
| មានម៉ាស៊ីន | ៩៥ | ៥០០-១.០០០គក្រ | ៣-៥ សេះ |

- ឧបករណ៍នេសាទ របស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

**តារាង ៣:**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង |
|---|---|---|---|
| មង | ដៃ | ២០ | ១៨០០ម |
| សន្ទូចរនង | ផ្លែ | ១០ x ២០០ | ២០០០ ផ្លែ |

-ប្រភេទទូកកាណូត របស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ:

**តារាង ៤:**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| គ្មានម៉ាស៊ីន | ៤ | ៥០០ គក្រ | - |
| មានម៉ាស៊ីន | ៦ | ៥០០-១.០០០គក្រ | ៥-៧ សេះ |

- ឧបករណ៍នេសាទរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

**តារាង ៥:**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង |
|---|---|---|---|
| មង ពាក់ | ដៃ | ៥០ | |
| សន្ទូចរនង | ផ្លែ | ៥០ | |

-ប្រភេទទូកនេសាទរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

**តារាង ៦:**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| គ្មានម៉ាស៊ីន(ទូកត្នោត) | ៨ | ១៥០គក្រ | - |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

**តារាង ៧:**

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គ.ក) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៦០ថ្ងៃx២០នាក់x៣គក្រ=១២០០០គក្រ | ១២០ថ្ងៃx១០០នx៣គក្រ=៣៦០០០គក្រ | ៤៨០០០គក្រ |
| អន្ទង់ | ៥០ថ្ងៃx៣នាក់x១.៥ គក្រ= ២២៥គក្រ | | ២២៥ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **កៀនឃ្លាំង** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និង ប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវដាំឡើង និងនាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

**តារាង ៨:**

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតិឱ្យប្រើ | | | ចំនួនអ្នកនេសាទ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (គ្រឿង/វង់/ផ្លែ) | |
| ដៃបឹងជាប់ជើង | ខែកក្កដា-មករា | មងពាក់ | ៥០ម/នាក់ | ២.៥ -៩ហ៊ុន | ២០នាក់ |
| | ខែមីនា-ឧសភា | សំណាញ់ | ១៥វង់ | ក្រឡា ៣,៥ហ៊ុន | ១៥នាក់ |
| | ខែវិច្ឆិកា-ឧសភា | សន្ទូចរនង | ២០០ផ្លែ/នាក់ | ផ្លែលេខ១៤ | ១៥នាក់ |
| | ខែធ្នូ-ឧសភា | សន្ទូចបង្កៃ | ១០០ផ្លែ/នាក់ | ផ្លែលេខ១៤ | ១០នាក់ |
| | ខែធ្នូ-ឧសភា | លប | ៣គូ/នាក់ | ១ខ១,៥ម | ៥នាក់ |
| | ខែធ្នូ-ឧសភា | សន្ទូចបង្កៃ | ១០០ផ្លែ/នាក់ | ផ្លែលេខ១៤ | ៩នាក់ |
| | ខែធ្នូ-ឧសភា | លប | ៣គូ/នាក់ | ១ខ១,៥ម | ៥នាក់ |

### គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

**តារាង ៩ៈ**

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងតាប្រាក់ | ២៤ ហត | ៣០x១០០x២ម | ស្តារជីកដោយគ្រឿងចក្រ ឬអង្ករពលកម្ម | ខែមេសា ២០០៨ | ខែមីថុនា ២០០៨ | ១៥០០ដុល្លារ ឬអង្ករ៣០ តោន |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

**តារាង ១០ៈ**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទ នៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| មេទឹកតាប្រាក់ | ១០០x៥០០ម | ព្រៃលិចទឹក | -ផ្សព្វផ្សាយ<br>-បោះបង្គោល<br>-ដាក់សម្រាស់<br>-បោះស្លាកសញ្ញា<br>-ចុះការពារ | ខែមករា ២០០៨ | ខែកុម្ភៈ ២០០៨ | ៤២០ដុល្លារ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

**តារាង ១១ៈ**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| មេទឹកតាគង់ | ១.៥ហត | ដើមរាំង | -បណ្តុះកូនឈើ<br>-បោះស្លាកសញ្ញា | ខែវិច្ឆិកា ២០០៨ | ខែមីថុនា ២០០៩ | ១៥០ដុល្លា |

| | | | | | | |
|---|---|---|---|---|---|---|
| | | | -ថែរក្សា | | | |
| មេទឹកតាព្រេង | ១,៨ហត | ដើមរាំង និងត្រស់ | -បណ្តុះកូនឈើ<br>-ដាំ<br>-បោះស្លាកសញ្ញា<br>-ថែរក្សា | ខែវិច្ឆិកា ២០០៨ | ខែមិថុនា ២០០៩ | ២៥០ដូ |
| មេទឹកតាប្រាក់ | ៣៩,៥ ហត | ដើមរាំង និងត្រស់ | -បណ្តុះកូនឈើ<br>-ដាំ<br>-បោះស្លាកសញ្ញា<br>-ថែរក្សា | ខែវិច្ឆិកា ២០០៩ | ខែមិថុនា ២០១០ | ១៥៧៥ដូ |
| មេទឹកតាអឹម | ៣១,៥ហត | ដើមរាំង និងត្រស់ | -បណ្តុះកូនឈើ<br>-ដាំ<br>-បោះស្លាកសញ្ញា<br>-ថែរក្សា | ខែវិច្ឆិកា ២០១០ | ខែមិថុនា ២០១០ | ១៤០០ដូ |

**គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោម:

**តារាង ១២:**

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ២៧ | ឆ្លិន និងអណ្តែង | ១៥០០០កូន | ខែវិច្ឆិកា ២០០៨ | ខែកក្កដា ២០០៩ |

**គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍**

**តារាង ១៣:**

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលថវិកា | ខែមេសា ២០០៨ | ខែមេសា ២០០៨ | ៥០០/នាក់<br>១០០០/នាក់ | |
| ភាគទានប្រចាំឆ្នាំ | ប្រមូលថវិកា<br>សមាជិកចូល១នាក់/៥០០រៀល<br>សមាជិកចូល១នាក់/១០០០រៀល | ខែមេសា ២០០៨ | ខែមេសា ២០១០ | | |

### គ-៧ ផែនការកសាងក្នុងសហគមន៍នេសាទ

**តារាង ១៤:**

| ប្រភេទសកម្មភាព | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ |
| ទិញកាណូតស.ន | ១គ្រឿង | ១០០០ដុល្លារ | ខែកក្កដា ២០០៩ | ខែសីហា ២០០៩ |
| សង់ស្នាក់ការស.ន | ១ខ្នង | ២.៥០០ដុល្លារ | ខែមករា ២០១០ | ខែឧសភា ២០១០ |

### គ-៨ ផែនការអភិវឌ្ឍន៍នៅក្នុងសហគមន៍នេសាទ

**តារាង ១៥:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ធ្វើបង្គន់អនាម័យ | ១០ | ១០បង្គន់ | ៣០០ដុល្លារអាមេរិក | ខែមករា ២០០៩ | ខែកក្កដា ២០០៩ |
| ផ្តល់ធុងចម្រុះទឹកស្អាត | ៥០ | ៥០ធុង x ២០ដុល្លា | ៥០០ដុល្លារអាមេរិក | ខែមករា ២០០៨ | ខែមករា ២០០៨ |

### គ-៩ ផែនការត្រទ្រង់ជីវភាព

**តារាង ១៦:**

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| មាន់ចិញ្ចឹម | ២៥ | ៧៥ ក្បាល | ២២៥ ដុល្លារ | ខែមករា ២០០៨ | ខែមករា ២០០៨ |
| ជ្រូក | ៧ | ៧ ក្បាល | ៣៥០ ដុល្លារ | ខែមករា ២០០៨ | ខែធ្នូ ២០០៨ |
| ទាកាប៉ាចិញ្ចឹម | ២៧ | ៨១ ក្បាល | ៣២៤ ដុល្លារ | ខែមករា ២០០៩ | ខែមករា ២០០៩ |
| គោមេ | ៥ | ៥ ក្បាល | ១៥០០ ដុល្លារ | ខែវិច្ឆិកា ២០១០ | ខែធ្នូ ២០១០ |
| ក្របីមេ | ២ | ២ ក្បាល | ៧០០ ដុល្លារ | ខែវិច្ឆិកា ២០១០ | ខែធ្នូ ២០១០ |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម:

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែល

ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្រ្តទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គៀនឃ្លាំង រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

**តារាង ១៧:**

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ចុះត្រួតពិនិត្យការប្រើប្រាស់ ឧបករណ៍នេសាទនៅបឹងវែង គំនៀរ និងជាប់ជើង | ការធ្វើនេសាទនៅក្នុងបឹងធំមិនហួសកំរិតឡើយ | ៧០០ ដុល្លា | -សហគមន៍<br>-អង្គការក្រៅរដ្ឋាភិបាល<br>-គម្រោងរដ្ឋាភិបាល | ខែមករា-ឧសភា ២០០៨ | ខែមករា-ឧសភា ២០១០ | |
| ២. ការកែលំអដែននេសាទ | ស្តារបឹងគំនៀរ ៣០មx១០០មx២ម | កន្លែងដែលស្តារក្នុងបឹងមិនរីងនៅរដូវប្រាំង | ១៥០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែមេសា ២០០៨ | ខែមិថុនា ២០០៨ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | បោះផ្លាក ដាក់ដែកលួស បោះបង្គោល និងផ្សព្វផ្សាយ | មានតំបន់អភិរក្សទំហំចំនួន ០,៣ ហតនៅក្នុងបឹងគំនៀរ | ៤២០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែមករា ២០០៨ | ខែមេសា ២០០៨ | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំព្រៃលិចទឹកនៅមេទឹកតាព្រេង តាគង់ តាប្រាក់ និងតាអឹម | ទំហំដី៧១,៣ហតនឹងមានព្រៃរាំង និងត្រស់ដុះឡើងវិញ | ៣៣៧៥ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែវិច្ឆិកា ២០០៨ | ខែមិថុនា ២០១០ | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីតាមស្រះ | ស្រះក្នុងភូមិចំនួន២៧មានចិញ្ចឹមត្រីឆ្លិន និងអណ្តែង | ១៥.០០០កូនត្រី | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែវិច្ឆិកា ២០០៨ | ខែមីនា ២០០៩ | |
| ៦. ផែនការរកប្រាក់ចំណូលសហគមន៍ | ប្រមូលថវិកាពីសមាជិកស.ន | សមាជិកស.ន នឹងបង់ប្រាក់គ្រប់ចំនួនទាំងមាជិកភាព និងប្រចាំឆ្នាំ | | -គណៈកម្មការស.ន និងប្រធានភូមិ | ខែមេសា ២០០៨ | ខែមេសា ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧. ផែនការកសាងក្នុងស.ន | សង់ស្នាក់ការសហគមន៍ និង ទិញកាណូតសហគមន៍ | ស.ន នឹងមានស្នាក់ការនឹងទីកន្លែងសម្រាប់ប្រជុំពិភាក្សា និង ស.ននឹងមានកាណូតសម្រាប់ចុះធ្វើការងារផ្សេងៗរបស់សហគមន៍ | ៣៥០០ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល<br>-ថវិកាបដិភាគស.ន | ខែកក្កដា ២០០៩ | ខែឧសភា ២០១០ | |
| ៨. ផែនការសុខភាព និង អនាម័យ | ធ្វើបង្គន់អនាម័យ ធុងចម្រោះទឹកស្អាត និង ពាងយក្ស | កាត់បន្ថយភាពកខ្វក់ និងជំងឺឆ្លងនៅក្នុងភូមិ | | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល<br>-ថវិកាបដិភាគស.ន | ខែឧសភា ២០០៨ | ខែកក្កដា ២០០៩ | |
| ៩. ផែនការទ្រទ្រង់ជីវភាពសមាជិកស.ន | ចិញ្ចឹមមាន់ ទា ជ្រូក គោ និងក្របី | សមាជិកសហគមន៍ចំនួន៦៦ គ្រួសារនឹងអាចរកចំណូលបន្ថែមតាមរយៈការចិញ្ចឹមសត្វ | ៣០៥៩ ដុល្លា | -គម្រោងរដ្ឋាភិបាល<br>-អង្គការក្រៅរដ្ឋាភិបាល | ខែមករា ២០០៨ | ខែធ្នូ ២០១០ | |

| សកម្មភាព | តារាងកម្មវិធីការងារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | | |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | |
| ២. ការកែលំអដែននេសាទ | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម តាមស្រះ | | | | | | | | | | | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | |
| ៧. ផែនការកសាងក្នុងសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | |
| ៨. ផែនការសុខភាព និងអនាម័យ | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | |
| ៩. ផែនការទ្រទ្រង់ជីវភាពសមាជិកសហគមន៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

បានឃើញ និងបញ្ជូនមក

លោកនាយ[ក] រដ្ឋបាលជលផល.......

នាយសង្កាត់រដ្ឋបាលជលផល.....

.......ថ្ងៃទី...10.......ខែ....9.....ឆ្នាំ ២០០8

បានឃើញ

មេឃុំ...........

.....ថ្ងៃទី..10.....ខែ.....9.....ឆ្នាំ ២០០8

.....ថ្ងៃទី....8....ខែ...9.....ឆ្នាំ ២០០8

ប្រធានគណៈកម្មការសហគមន៍នេសាទ

លេខ :............

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ.........ឆ្នាំ ២០០

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

លេខ :...

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ"

.......ថ្ងៃទី...27.....ខែ...11....ឆ្នាំ ២០០8

នាយអធិការដ្ឋាន... រដ្ឋបាលជលផល...

លេខ :...

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន រដ្ឋបាលជលផល...

.......ថ្ងៃទី...21.....ខែ...10.....ឆ្នាំ ២០០ 8

នាយខណ្ឌរដ្ឋបាលជលផល.......